អង្គការរ៉ឺម៉កកង់បីសម្រាប់កុមារ R4C

**សកម្មភាព** ៖ **ល្បែង ផ្គុំគ្រាប់សណ្តែកជារូបភាព**

**សិក្សាសង្គម**

គំនូរសកម្មភាពកសាង(ការយល់ដឹង និងការពេញចិត្តចំពោះសិល្បៈតាមរយៈការបង្កើតរូបភាព)

**បុរេគណិត**

បរិមាណ និងចំនួន(ស្គាល់ យល់លេខតាង រាប់ចំនួន និងគណនាលេខសាមញ្ញ។

**ភាសាខ្មែរ**

ប្រើពាក្យសម្ដីកាយវិការ និងនិមិត្តសញ្ញាដើម្បីទំនាក់ទំនង (និមិត្តសញ្ញាតំណាងឱ្យសត្វ និងវត្ថុនានា)។

ការស្គាល់តួអក្សរ (ការប្រើញាណរបស់ខ្លួនដើម្បីអភិវឌ្ឍបមណិនសមត្ថភាពទាំង៦)

**គោលបំណង** ៖

(សិក្សាសង្គម) ប្រាប់បានពីរបៀបគូរ ហែករូបងាយៗតាមស្នាមចុច និងផាត់ព៌ណរូបភាពផ្សេងៗ និងបង្ហាញពីសកម្មភាពផ្សេងៗទៀតដែលបានបង្កើតស្នាដៃ។

(បុរេគណិត) ប្រាប់បានពីចំនួនលេខ និងយលន័យពី១ដល់២០តាមលំដាប់លំដោយ ឬលើសពីនេះ។

(ភាសាខ្មែរ) ៖ប្រាប់បានពីឈ្មោះសត្វតាមរយៈការធ្វើចលនាកាយវិការគ្រាប់តាមនិមត្តសញ្ញា។

ប្រាប់ឈ្មោះសត្វវត្ថុផ្សេងដោយស្ដាប់សម្លេង ឬ សង្កេតកាយវិការ។

ស្ដាប់ និងបែងចែកសូរសម្លេងដូចជា សូសម្លេងសត្វ សម្លេងមនុស្ស និងដឹងពីប្រភពសម្លេង។

**កម្រិតសិក្សា** ៖ ទាប មធ្យម ខ្ពស់

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ បោះពុម្ពរូបភាពសត្វទាំង១២ (ជ្រើសរើសយកសត្វណាមួយដែលអ្នកពេញចិត្ត) សណ្តែកដែលមានទំហំផ្សេងៗគ្នា និងពណ៌ផ្សេងៗគ្នាដែរ ធ្វើការស្អិត ធ្វើរូបភាពមួយដោយខ្លួនឯង សម្រាប់បង្ហាញទៅកាន់ក្មេងៗក្នុងថ្នាក់។

**ការរៀបចំ** ត្រៀមសន្លឹកកិច្ចការដាក់កាវនៅក្នុងកូនចានត្រៀមប្រអប់ផ្សេងៗ សម្រាប់ដាក់គ្រាប់សណ្តែកដែលមានទំហំផ្សេងនិងពណ៌ផ្សេងៗទាំងនោះ។ ជ្រើសរើសកន្លែងផ្សេងៗគ្នាសម្រាប់ដាក់គ្រាប់សណ្តែកនៅជុំវិញពួកគេ និងស្លាបព្រា

**សេចក្តីណែនាំ ៖**

1. បង្ហាញក្មេងៗពីរូបភាពដែលអ្នកបានធ្វើរួច និងនិយាយពីគ្រាប់សណ្តែកដែលខុសគ្នា ដែលសម្រាប់ប្រើ និងពណ៌ និងទំហំផ្សេងគ្នា
2. ពន្យល់ក្មេងៗពីរបៀបដែលអ្នកចង់បានពួកគេដើម្បីធ្វើល្បែងសកម្មភាពនេះទៅតាមសមត្ថភាពរបស់ពួកគេចែកន្លឹកកិច្ចការ កាវស្អិត និងប្រអប់ដែលសម្រាប់ដាក់សណ្តែកទាំងនោះ
3. ប្រាប់ក្មេងនីមួយៗកន្លែងដែលអ្នកដាក់គ្រាប់សណ្តែកពណ៌ទាំងនោះ

   សេចក្តីណែនាំ

   - ☐ លាបនៅកន្លែងតូចៗជាមួយការស្អិត និងត្រូវទុកដាក់គ្រាប់សណ្តែក/គ្រាប់បាយ
   - ☐ ប្រើការឱ្យបានគ្រប់គ្រាន់ ក្នុងការបិទគ្រាប់សណ្តែកធំ និងតូច
   - ☐ កុំលាបការជាកន្លែងធំពេក ឬក្រាស់ពេក ព្រោះវាមិនងាយស្ងួត
   - ☐ វាគឺជាការបរសើរជានេះក្នុងការចាប់ផ្តើម ពាក់កណ្តាល និងរហូតដល់បញ្ចប់
4. ប្រាប់ពួកគេឱ្យដើរទៅយកគ្រាប់សណ្តែកដែលមានទំហំតូច និងត្រឡប់ទៅយកគ្រាប់សណ្តែកទំហំផ្សេងទៀត

5. នៅចុងបញ្ចប់ល្បែងនេះផងដែរ ប្រាប់ក្មេងៗនូវកន្លែងដែលទុកសណ្តែក និងទុកពួកវានៅកន្លែង។
6. ប្រសិនបើមានពេលលេងច្រើនជាងហ្នឹង អាចឱ្យក្មេងៗដាក់គ្រាប់សណ្តែកកន្លែងដើមវិញ ដើម្បីបានលេងបន្តទៀតក៏បាន

**ការប្រែប្រួល៖**

សម្រាប់ក្មេងៗដែលមានកម្រិតទាប  ពួកគេគួរតែប្រើសកម្មភាពតូចៗដែលប្រើជាមួយគ្រាប់សណ្តែកដែលមានទំហំធំជាង  និងដោយប្រើម្សុលក្នុងការចាប់គ្រាប់សណ្តែកទាំងនោះដាក់តាមគ្រោងរូបភាពទាំងនោះបើសម្រាប់ក្មេងដែលមានកម្រិតខ្ពស់វិញ គួរតែប្រើគ្រាប់សណ្តែកដែលមានទំហំតូចដូចជា៖ គ្រាប់សណ្តែកតូច គ្រាប់រុក្ខជាតិ គ្រាប់អង្ករ ជាដើម...។